**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 27-Sep-2012, 15:54
CMS/CFO: Uch Arun

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីក្តីរបស់លោក អៀង សារី

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ២៧ ខែ កញ្ញា ឆ្នាំ ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឲ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឲ្យផ្តល់ភស្តុតាង ទាក់ទងនឹងការស្តាប់ចម្លើយនេះ**

---

**<u>ដាក់ដោយ:</u>**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**<u>ចម្លងជូន:</u>**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ចៅក្រមបម្រុង **ឆូ មន្ធី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្ដីរបស់លោក ("មេធាវីការពារក្ដី") អនុលោមតាមវិធាន ៩៣ និងវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុង) សូមស្នើសុំអង្គជំនុំជម្រះសាលាដំបូងស្វែងរកការបញ្ជាក់ពីការិយាល័យសហចៅក្រមស៊ើបអង្កេត "ក.ស.ច.ស" ទាក់ទងនឹងកាលៈទេសៈនៃការសួរសំណួរដល់សាក្សី នង សុផង់ ដែល ក.ស.ច.ស បានធ្វើ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតដែលបានសួរសំណួរ នង សុផង់ ឲ្យផ្ដល់ភស្តុតាងទាក់ទងនឹងកាលៈទេសៈទាំងនេះ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះថា ខ្សែអាត់ថតសំឡេងនៃការស្ដាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ បង្ហាញថា អ្នកស៊ើបអង្កេតបានរៀបចំការស្ដាប់ចម្លើយសាក្សីនេះជាមុន ដែលមិនបានកត់ត្រា ឬថតយកសំឡេង ដែលការស្ដាប់ចម្លើយនេះមិនត្រូវបានបញ្ជាក់នៅក្នុងការស្ដាប់ចម្លើយសាក្សីជាសង្ខេបដែលបានរៀបចំឡើងដោយ ក.ស.ច.ស ទេ។ មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្ដាប់ចម្លើយ នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតដែលបានស្ដាប់ចម្លើយនោះដើម្បីបញ្ជាក់ ក. ថាតើតាមពិតមានកំណត់ហេតុនៃការស្ដាប់ចម្លើយ នង សុផង់ ដែលបានធ្វើឡើងនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដែរឬទេ ខ. រយៈពេលនៃការស្ដាប់ចម្លើយនោះ គ. បុគ្គលដែលបានចូលរួម ឃ. ឯកសារ និងសម្ភារៈផ្សេងៗទៀតដែលបានបង្ហាញដល់ នង សុផង់ ប្រសិនបើមាន និង ង. ប្រសិនគ្មានការកត់ត្រា ឬថតយកសំឡេងទេ បញ្ជាក់ពីមូលហេតុនៃការគ្មានការកត់ត្រាដូចនេះ។ លោក អៀង សារី មានសិទ្ធិសួរដេញដោលលើសក្ខីកម្មរបស់សាក្សី ដែលនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក រួមមានជាពិសេស កំណត់ហេតុនៃការស្ដាប់ចម្លើយដែលបានធ្វើឡើងដោយ ក.ស.ច.ស។ ដើម្បីជាអំណះអំណាងរបស់ខ្លួន មេធាវីការពារក្ដីបានដាក់បញ្ចូលអង្គហេតុ និងទឡ្ហីករណ៍គតិយុត្តិពាក់ព័ន្ធទាំងអស់ដោយដកស្រង់ចេញពីសារណាមុនៗទាក់ទងនឹងភាពខុសគ្នា និងភាពមិនស៊ីសង្វាក់គ្នារវាងចម្លើយសាក្សីដែលធ្វើឡើងដោយ ក.ស.ច.ស និងខ្សែអាត់ថតសំឡេងពីបទសម្ភាសន៍នានា[1]។ ដើម្បីជាជំនួយបន្ថែមដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃដល់កិច្ច

---

[1] សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី អ.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសំឡេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ E224; សំណើរបស់ អៀង សារី សុំស្ដាប់ការបង្ហាញភស្តុតាង ពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្ដាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថាជាការលេងឆ្កិនឆ្កែក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E221; លិខិតពីក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្រោមកម្មវត្ថុ "ការជំទាស់ទៅនឹងចម្លើយសាក្សី" ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នា ២០១២ ឯកសារ E96/7/1;

ខិតខំប្រឹងប្រែងរបស់មេធាវីការពារក្ដីដល់ការបំភ្លឺភាពមិនប្រក្រតីនៃកិច្ចស៊ើបសួរ មេធាវីការពារក្ដីសូមជូនភ្ជាប់មកជាមួយនឹងសំណើនេះនូវសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបីរបស់ខ្លួន។

**សារចារ**

១. ដើម្បីគាំទ្រដល់សំណើនេះ មេធាវីការពារក្ដីសូមលើកអង្គហេតុពាក់ព័ន្ធដូចខាងក្រោម ៖

ក. នៅក្នុងខ្សែអាត់សំឡេងនៃកំណត់ហេតុស្ដាប់ចម្លើយ នង សុផង់ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បាននិយាយយោងចំនួនពីរដងទៅសំដីរបស់ នង សុផង់ ដែលបាននិយាយមួយថ្ងៃមុន ពោលគឺនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩[2]។ ឧទាហរណ៍ មុននឹងសួរសំណួរទាក់ទងនឹង ប៉ង់ (Pang) អ្នកស៊ើបអង្កេតម្នាក់បាននិយាយថា "កាលពីម្សិលមិញ អ្នកបាននិយាយប្រាប់ខ្ញុំទាក់ទងនឹងមនុស្សម្នាក់ ឈ្មោះប៉ង់ ..."[3]។ កំណត់ហេតុនៃការស្ដាប់ចម្លើយដែល ក.ស.ច.ស បានធ្វើជាមួយនឹង នង សុផង់ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ នេះ មិនបានបង្ហាញថាមានការស្ដាប់ចម្លើយ នង សុផង់មុនឡើយ[4]។

ខ. នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ក្នុងអំឡុងពេលនៃការសួរដេញដោលដែលធ្វើឡើងដោយមេធាវីការពារក្ដី និងបន្ទាប់ពីការពិភាក្សាយ៉ាងយូរដែលមានសេចក្ដីសង្ខេបដូចខាងក្រោម នង សុផង់ បានបញ្ជាក់ថា តាមពិត គាត់បានជួបជាមួយនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មុននឹងការស្ដាប់ចម្លើយលើកទីមួយរបស់គាត់ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩។ គាត់បាន

---

លិខិតពីមេធាវីការពារក្ដីរបស់លោក អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្រោមកម្មវត្ថុ "ច្របូកច្របល់/បាត់ឯកសារសំឡេងនៅក្នុងសំណុំរឿង" ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២; លិខិតពីមេធាវីការពារក្ដីរបស់លោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្រោមកម្មវត្ថុ "សំណើសុំខ្សែអាត់ថតសំឡេង/វីដេអូអំពីការស្ដាប់ចម្លើយសាក្សីមួយចំនួនរបស់ អ.ស.ច.ស" ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២។

[2] ឯកសារ D200/3R, ០១: ២៥: 00-០១:២៦:00; 00:0៧:៥៥-00:0៨: ១៩។

[3] ឯកសារ D200/3R, ០១:២៥:00- ០១:២៦:00។

[4] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ E3/64។ ដូចគ្នានេះដែរ របាយការណ៍ដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានដាក់ ទាក់ទងនឹងការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ ក.ស.ច.ស មិនបានបញ្ជាក់ថាមានការស្ដាប់ចម្លើយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ រវាង នង សុផង់ និងអ្នកស៊ើបអង្កេតទេ។ សូមមើលរបាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D200/1។

បញ្ជាក់ថា គាត់មិនជឿថាមានការធ្វើកំណត់ហេតុនៃការជួបមុននោះទេ ហើយអ្នកស៊ើបអង្កេត ក.ស.ច.ស បាននិយាយជាមួយនឹងរូបគាត់អស់រយៈពេលប្រមាណជា ១ ម៉ោង[5]។

២. ខាងក្រោមនេះគឺជាផ្នែកពាក់ព័ន្ធនឹងការនិយាយឆ្លើយឆ្លងក្នុងសាលសវនាការ នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ចំពោះការសួរសំណួរនានា ដែលនាំដល់ការដាក់សំណើនេះ ៖

ក. សហមេធាវីការពារក្តីអន្តរជាតិ Michael G. Karnavas បានចាប់ផ្តើមសួរសំណួរដល់ នង សុផង់ ទាក់ទងនឹងកាលៈទេសៈនៃការស្តាប់ចម្លើយលើកទីមួយដែលមានកត់ត្រា ឬមានថតយកសំឡេង[6]។

ខ. លោកប្រធាន និល ណុន បានបញ្ឈប់ការសួរសំណួរទាំងនេះ ដោយសួរថា ៖ "ចំពោះសំណួរដែលអ្នកបានសួរសាក្សីនោះ តើមានទំនាក់ទំនងទៅនឹងបទចោទនានា ប្រឆាំងនឹងកូនក្តីរបស់អ្នកទេ?" ហើយ "តើអ្នកធ្លាប់អានកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះទេ នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ?"[7] នៅពេលលោក Karnavas ប៉ុនប៉ងឆ្លើយតបទៅនឹងសំណួរទាំងនេះ លោកប្រធាន និល ណុន បានបញ្ឈប់ ហើយអានផ្នែកមួយនៃវិធាន ៧៦ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងមោឃភាព និងបញ្ជាក់ថា កំហុសផ្នែកនីតិវិធីមិនត្រូវលើកមកនិយាយ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ។ លោកប្រធាន និល ណុន បានបញ្ជាក់ថា សំណួររបស់មេធាវីការពារក្តី ហាក់ដូចជាមានទំនាក់ទំនងជាមួយនឹងកំហុសផ្នែកនីតិវិធី ដោយមិនទាក់ទងនឹងបទចោទនានាប្រឆាំងនឹងលោក អៀង សារី ឡើយ[8]។

គ. លោក Karnavas បានពន្យល់ថា គាត់មិនបានព្យាយាមសុំមោឃភាពនៃកិច្ចស៊ើបសួរទេ ប៉ុន្តែមានបំណងសួរសំណួរពាក់ព័ន្ធទៅនឹងអ្វីៗដែលបានកើតឡើង ក្នុងអំឡុងពេលនៃការស្តាប់ចម្លើយដែលមិនបានកត់ត្រា ឬថតយកសំឡេង ដូចជាថា ៖ "តើមានការបង្ហាញឯកសារដល់សាក្សី

---

[5] ប្រតិចារឹក, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/123.1 ទំព័រ ៤៥-៤៦។

[6] *ដូចខាងលើ* ទំព័រ ២៩-៣២។

[7] *ដូចខាងលើ* ទំព័រ ៣២-៣៣។

[8] *ដូចខាងលើ* ទំព័រ៣៤។

ឬទេ? តើការជួបសន្ទនានោះមានរយៈពេលប៉ុន្មាន? ហេតុអ្វីបានជាការស្តាប់ចម្លើយមុន មិនត្រូវបានថតសំឡេង? តើការស្តាប់ចម្លើយមុនមានគោលបំណងអ្វី?"[9]

ឃ. បន្ទាប់មកចៅក្រម Lavergne បានបញ្ជាក់ថា "យើងមិនធ្វើការពិភាក្សាអំពីការស៊ើបអង្កេតនៅក្នុងពេលនេះទេ។ ... យើងនៅទីនេះដើម្បីសិក្សា និងត្រួតពិនិត្យបញ្ហាសារធាតុ។ បញ្ហាពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ មិនត្រូវលើកជាសំណួរដែលមិនសំខាន់ និងច្រំដដែលនោះទេ។ ... ខ្ញុំជឿថា យើងបានស្វែងយល់បញ្ហាយ៉ាងល្អិតល្អន់ ហើយនៅពេលនេះយើងត្រូវតែបន្តទៅចំណុចបន្ទាប់ទៀត"[10]។

ង. លោក Karnavas បានឆ្លើយតបថា សំណួរដែលគាត់មានបំណងសួរទាំងនេះ "គឺជាសំណួរយ៉ាងសំខាន់ក្នុងការកំណត់ពីទម្ងន់ ប្រសិនបើមាន សម្រាប់សក្ខីកម្មរបស់សាក្សី នៅក្នុងតុលាការនេះ ពីព្រោះថា សាក្សីពេលខ្លះ ត្រូវនិយាយយោងទៅលើផ្នែកខ្លះនៃសក្ខីកម្មរបស់គាត់ ដោយផ្អែកទៅលើកំណត់ហេតុនៃការស្តាប់សាក្សី"[11]។

ច. មកដល់ត្រង់ចំណុចនេះ អង្គជំនុំជម្រះបានសម្រាកពីកិច្ចដំណើរការនីតិវិធី។ បន្ទាប់ពីបានចូលមកវិញ លោកស្រីចៅក្រម Cartwright បានបញ្ជាក់ថា ៖

> វិធានទូទៅគឺថា មានសច្ចធារណ៍គតិយុត្តិនៃសុចរិតភាពនៃកិច្ចស៊ើបអង្កេត ដែលថា រាល់ការព្រួយបានរម្ភពាក់ព័ន្ធនឹងវិធីសាស្ត្រ ឬជាកម្មវត្ថុមួយដែលកើតមានឡើងនៅក្នុងអំឡុងពេលស៊ើបអង្កេតនេះ ត្រូវតែលើកឡើង ក្នុងអំឡុងពេលនៃកិច្ចស៊ើបអង្កេត។ ហើយនៅពេលនេះ ពោលគឺក្នុងពេលសវនាការ ដូចលោកចៅក្រម Lavergne បានបញ្ជាក់ហើយថា ការស៊ើបអង្កេតត្រូវបានចាត់ថាជាចំណុចចាប់ផ្តើម ហើយអាចជំទាស់តវ៉ាតែនៅក្នុងកិច្ចស៊ើបសួរ លើកលែងតែករណីមួយចំនួនប៉ុណ្ណោះ។ រាល់ការជំទាស់ទាំងនេះមិនមែនត្រូវតែពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេសទេ ក៏ប៉ុន្តែវាត្រូវតែពាក់ព័ន្ធទៅនឹងខ្លឹមសារផងដែរ។ ហើយការលើកឡើងអំពីករណីលើកលែងនោះ អ្នកត្រូវតែបំពេញលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាដំបូងថា អ្នកមានកង្វល់ដែលមានសំអាងច្បាស់លាស់

[9] *ដូចខាងលើ* ទំព័រ ៣៤-៣៥។

[10] *ដូចខាងលើ* ទំព័រ ៣៦-៣៧។

[11] *ដូចខាងលើ* ទំព័រ ៣៨។

ទៅលើភាពគួរឲ្យជឿជាក់បាននៅត្រង់ផ្នែកណាមួយនៃកិច្ចស៊ើបអង្កេត។ សូមលើកពាក្យពេចន៍ដ៏ល្បីល្បាញក្នុងច្បាប់កុំមិនឡូនោះ អ្នកមិនអាចងាកទៅធ្វើអ្វីមួយ ដែលអ្នកមិនដឹងអំពីលទ្ធផលនោះទេ។ អ្នកចាំបាច់ត្រូវបង្ហាញដល់អង្គជំនុំជម្រះសាលាដំបូងថា អ្នកមានសំអាងហេតុគ្រប់គ្រាន់ ដើម្បីត្រឡប់ទៅមើលកិច្ចស៊ើបអង្កេតឡើងវិញ។ ដូច្នេះ យើងសូមសម្រេចថា លោកគ្រាន់តែសួរសំណួរទាំងឡាយដែលលោកចង់សួរសាក្សីនេះទៅបានហើយ[12]។

## I. ច្បាប់ និងឧទ្ធរណ៍

### ក. លោក អៀង សារី មានសិទ្ធិក្នុងការតទល់ជាមួយនឹងសាក្សី និងពិនិត្យភស្តុតាង

៣. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា[13] និងមាត្រា ១៤ នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[14] (ដែលមាត្រានេះត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង[15] និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[16]) ធានាដល់សិទ្ធិរបស់ លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមានតម្លាភាព ដែលរួមបញ្ចូលទាំងសិទ្ធិក្នុងការពិនិត្យភស្តុតាងដាក់បន្ទុក និងសិទ្ធិទទួលបានការការពារក្តី។ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងពី "ការដេញដោល" នៅក្នុងកិច្ចដំណើរការនីតិវិធី

[12] *ដូចខាងលើ* ទំព័រ ៤៣-៤៤។

[13] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមាននៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស សិទ្ធិនារី និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

[14] មាត្រា ១៤(៣) នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា ៖

> ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ... (ង) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយ ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ...

[15] មាត្រា ១២(២) នៃកិច្ចព្រមព្រៀង ចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភីហត្ថលេខី"។

[16] មាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា អង្គជំនុំជម្រះវិសាមញ្ញ "ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដែលមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"។

របស់ អ.វ.ត.ក ដែលជាលទ្ធផល ការណ៍នេះធានាដល់សិទ្ធិរបស់ភាគីនានាក្នុងការតទល់គ្នាជាមួយនឹងសាក្សី ក្នុងការសួរដេញដោល និងជំទាស់តវ៉ាចំពោះសក្ខីកម្មរបស់សាក្សី។ សិទ្ធិក្នុងការតទល់គ្នាជាមួយសាក្សី/ពិនិត្យភស្តុតាង ត្រូវរងការរំលោភបំពាន ប្រសិនបើ លោក អៀង សារី ត្រូវបានហាមឃាត់មិនឱ្យសួរសំណួរនានា ដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងភាពអាចជឿទុកចិត្តបាននៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងសក្ខីកម្មក្នុងសាលសវនាការ និងទម្ងន់ដែលអាចផ្តល់ឱ្យដល់កំណត់ហេតុ និងសក្ខីកម្មទាំងនោះ។ វាអាចមានលក្ខណៈស្មើនឹងការបំពេញការងារដោយងងឹតងងុលដោយចេតនា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងរារាំងមេធាវីការពារក្តី មិនឱ្យបើកបង្ហាញពីភាពមិនប្រក្រតីក្នុងដំណើរការនៃកិច្ចស៊ើបសួរដែលជះឥទ្ធិពលផ្ទាល់លើភាពអាចជឿជាក់បាននៃសាក្សី និងទម្ងន់ដែលត្រូវផ្តល់ឱ្យទៅកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងសក្ខីកម្មរបស់សាក្សី។ អង្គជំនុំជម្រះសាលាដំបូងមិនគួរបិទខ្លួនឯងពីព័ត៌មានដែលមានឥទ្ធិពលលើទម្ងន់នៃសក្ខីកម្មរបស់សាក្សី ដែលការណ៍នេះផ្ទុយទៅនឹងកាតព្វកិច្ចជារួមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងការពិត។

៤. ចៅក្រម Cartwright ដែលបាននិយាយតំណាងអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ថា មេធាវីការពារក្តី "មានសិទ្ធិសួរសំណួរស៊ើបសួរ និងសំណួរតទល់។ តាមពិត នេះគឺជាភារកិច្ចរបស់លោកក្នុងការសួរសំណួរទាំងនេះ"[17]។ ក.ស.ព ក៏បានទទួលស្គាល់ដូចគ្នានេះដែរថា មេធាវីការពារក្តីមានសិទ្ធិក្នុងការសួរដេញដោលពីភស្តុតាង និងថា "សេរីភាពមួយចំនួនគួរតែបានផ្តល់ឱ្យមេធាវីការពារក្តី" ដើម្បីត្រួតពិនិត្យកំណត់ហេតុនៃការស្តាប់ចម្លើយ និងប្រតិចារឹកជាមុន[18]។ លោក Tarik Abdulhak ជំនួយការជាន់ខ្ពស់នៃការិយាល័យសហព្រះរាជអាជ្ញា បានទទួលស្គាល់ថា "ប្រសិនបើមានភាពមិនស៊ីសង្វាក់គ្នាយ៉ាងធ្ងន់ធ្ងរ ហើយត្រូវសួរសំណួរគតិយុត្តិលើភាពអាចជឿទុកចិត្តបាននៃសាក្សីនោះ យើងគួរឯកភាពថា មេធាវីការពារក្តីគួរទទួលបានសេរីភាពមួយចំនួន ដើម្បីត្រួតពិនិត្យកំណត់ហេតុនៃការស្តាប់ចម្លើយ និងប្រតិចារឹកជាមុន ..."[19]។ ដូចគ្នានេះដែរ នៅពេលមេធាវីការពារក្តីបាន

---

[17] ប្រតិចារឹក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៦២។

[18] ប្រតិចារឹក ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E1/123.1 ទំព័រ ៤១។

[19] *ដូចខាងលើ* ទំព័រ ៤០-៤១។ ទោះជាយ៉ាងនេះក្តី ក.ស.ព បានអះអាងដោយខុសឆ្គងថា ការសួរសំណួររបស់មេធាវីការពារក្តីជាមួយនឹង នង សុផង់ ពាក់ព័ន្ធនឹងបទសម្ភាសន៍ជាមុនរបស់គាត់ជាមួយនឹង ក.ស.ច.ស គឺជា "ការប៉ុនប៉ងបង្កើតវិវាទកម្មក្លែងក្លាយ"។ ក.ស.ព ហាក់ដូចជាធ្វើការអះអាងថាមិនគួរអនុញ្ញាតឱ្យសួរសំណួរទាំងនោះឡើយ ពីព្រោះតាមគំនិតរបស់ខ្លួន នង សុផង់ បានផ្តល់ "សក្ខីកម្មដែលស៊ីសង្វាក់គ្នា និងគួរឱ្យទុកចិត្តបាន" ហើយអាចមាន "ការលំបាកក្នុងការបញ្ជាក់ពីភាពត្រឹមត្រូវនៃ

បង្ហាញពីភាពមិនប្រក្រតីទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ដែលធ្វើឡើងដោយ ក.ស.ច.ស (ពោលគឺ អង្គហេតុ ដែលកំណត់ហេតុស្តាប់នៃចម្លើយសាក្សីជាសង្ខេប ត្រូវបានធ្វើឡើងជាក់ស្តែងពីប្រតិចារឹកនៃការស្តាប់ចម្លើយត្រង់ៗតាមពាក្យពេចន៍ បង្ហាញថា ការស្តាប់ចម្លើយនោះត្រូវបានធ្វើឡើងដោយមានការរៀបចំ)[20] និងបានស្នើថា អង្គជំនុំជម្រះសាលាដំបូងគួរដោះស្រាយបញ្ហាទាំងនេះ មុននឹងចាប់ផ្តើមសួរដេញដោលសាក្សី។ លោក Dale Lysak ជំនួយការជាន់ខ្ពស់នៃការិយាល័យសហព្រះរាជអាជ្ញា បាននិយាយថា ៖

> ខ្ញុំសូមអរគុណលោកមេធាវីការពារក្តីដែលបានលើកបញ្ហានេះឡើងនៅពេលនេះ។ ខ្ញុំគិតថា ការលើកឡើងរបស់លោកនេះហាក់ដូចជាប្រញាប់ពេកបន្តិចហើយ ប៉ុន្តែ ខ្ញុំយល់នូវអ្វីៗដែលលោកបានលើកឡើងនោះហើយ។ ខ្ញុំបានឃើញប្រតិចារឹកនេះ បន្ទាប់ពីបានដាក់កាលពីម្សិលមិញជាភាសាបារាំង ហើយខ្ញុំបានមើលឃើញថា ប្រតិចារឹកដូចគ្នានឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរជាក់ស្តែង។ ហើយខ្ញុំយល់ឃើញនៅពេលនេះថា មេធាវីការពារក្តីកំពុងតែតវ៉ាថា ការស្តាប់ចម្លើយដែលមានថតសំឡេងមិនស៊ីសង្វាក់គ្នានឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរទេ។ អ្វីដែលខ្ញុំចង់និយាយយ៉ាងខ្លីនៅពេលនេះ គឺថា យើងនឹងសួរសំណួរដល់សាក្សីនេះ។ ប្រសិនបើមានបញ្ហាណាមួយនោះ បញ្ហានេះនឹងអាចមើលឃើញនៅក្នុងសក្ខីកម្មរបស់គាត់ .... ប៉ុន្តែនៅក្នុងដំណាក់កាលនេះ ខ្ញុំគិតថា យើងគួរបន្តសួរសំណួរទៅទៀត។ នេះហើយជាមូលហេតុក្នុងការអញ្ជើញសាក្សីឱ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការ[21]។

៩. តាមរយៈលោកចៅក្រម Lavergne អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាមានការយល់ច្រឡំលើគោលបំណងរបស់មេធាវីការពារក្តីក្នុងការសួរសំណួរដល់សាក្សី ទាក់ទងនឹងកាលៈទេសៈនៃការស្តាប់ចម្លើយដែលបានធ្វើឡើងដោយ ក.ស.ច.ស ដោយបានអះអាងថា សំណួររបស់មេធាវីការពារក្តី "មិន

---

ចម្លើយតបរបស់គាត់ និងចាត់ទុកចម្លើយតបរបស់គាត់ថាជាចម្លើយដែលគាត់បានផ្តល់ឱ្យការស្មានៗតែប៉ុណ្ណោះ"។ *ដូចខាងលើ* គំនិតរបស់ ក.ស.ព ទាក់ទងនឹងសក្ខីកម្មរបស់ នង សុផង់ គឺមិនពាក់ព័ន្ធថាតើបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តី អាចមានឥទ្ធិពលដល់ភាពអាចជឿជាក់បានរបស់សាក្សីដែរ ឬអត់ទេ។

[20] សារណាផ្សេងៗទៀតលើបញ្ហានេះ សូមមើល សំណើរបស់ អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរដែលកើតមាននូវភាពមិនប្រក្រតីដែលអាចនឹងចាត់ទុកថាជាការលេងល្បិចភ្នែក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E221។

[21] សូមមើល ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1 ទំព័រ ៦៤។

សំខាន់ និងច្រំដែល"[22]។ ការសួរសាក្សីពាក់ព័ន្ធនឹងកាលៈទេសៈនៃការស្តាប់ចម្លើយដែលក្នុងករណីនេះ សំណួរទាំងនេះទាក់ទងផ្ទាល់ទៅនឹងភាពអាចជឿជាក់បាននៃសាក្សី គឺជាកិច្ចការសំខាន់ និងមិនជាន់គ្នាឡើយ។ ការសួរសំណួរដែលពាក់ព័ន្ធនឹងសុចរឹតភាពនៃកំណត់ហេតុស្តាប់នៃការស្តាប់ចម្លើយសាក្សីគឺជាការចាំបាច់ជាពិសេស នៅក្នុងសំណុំរឿង ០០២/០១ នៅពេលពិនិត្យឃើញថា ក.ស.ព កំពុងព្យាយាមដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរាប់ពាន់ ដែលគ្មានកំណត់ហេតុជាខ្សែអាត់សំឡេង[23]។

៦. លោកប្រធាន និល ណុន[24] និងលោកចៅក្រម Lavergne[25] បានសន្និដ្ឋានដោយច្រឡំថា មេធាវីការពារក្តីកំពុងធ្វើមោឃភាពនៃកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តី ព្យាយាមកំណត់ថាតើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មានឥទ្ធិពលអ្វីខ្លះ និងកម្រិតណាដល់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ និងសក្ខីកម្មរបស់គាត់ នៅក្នុងសាលសវនាការ នៅពេលអ្នកស៊ើបអង្កេតបានជួបគាត់ ដើម្បីស្តាប់ចម្លើយដែលមិនបានកត់ត្រា ឬថតយកសំឡេង។ មេធាវីការពារក្តី *មិនដឹង និងមិនអាចដឹង* នូវអ្វីៗដែលបានកើតឡើងជាក់ស្តែងចំពោះ នង សុផង់ ក្នុងអំឡុងពេលប្រជុំសម្ភាត់ដែលមិនបានកត់ត្រា ឬថតយកសំឡេង នោះឡើយ មានជាអាទិ៍ ៖ តើសំណួរអ្វីខ្លះ ដែលបានប្រើដើម្បីសួរសាក្សី ហើយតើមានចម្លើយអ្វីខ្លះដែលបានផ្តល់ឱ្យទៅសាក្សី, តើសាក្សីបានទទួលព័ត៌មានដោយផ្ទាល់ដែរ ឬទេ ដូចជាការសួរសំណួរនាំមុខ ដោយស្នើសុំឱ្យមានការផ្តល់ចម្លើយ ឬមានបង្ហាញឯកសារនានា ឬការធ្វើឱ្យគាត់ចងចាំឡើងវិញត្រូវបានធ្វើ ឬត្រូវបានបំភ្លៃឡើងក្នុងកម្រិតណា។

---

[22] ប្រតិចារឹក ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/123.1 ទំព័រ ៣៧។

[23] សូមមើលសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E208; សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ហាភស្តុតាងផ្សេងៗទៀតជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III និងឧបសម្ព័ន្ធសាធារណៈ IV ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E208/2; សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១ ដល់ ១៦ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E96/8។

[24] ប្រតិចារឹក ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E1/123.1, ទំព័រ ៣២-៣៤។

[25] *ដូចខាងលើ* ទំព័រ ៣៦។

៧. "សំអាងហេតុដែលមានមូលដ្ឋានច្បាស់លាស់"[26] សម្រាប់សុំការបញ្ជាក់ពី ក.ស.ច.ស និងការស្តាប់ការបកស្រាយរបស់អ្នកស៊ើបអង្កេត គឺជាការបង្ហាញពីរូបភាពពេញលេញនៃការស្តាប់ចម្លើយដែលមិនបានកត់ត្រា ឬថតយកសំឡេង។ ភស្តុតាង ដែលមានតែ ក.ស.ច.ស ប៉ុណ្ណោះ ដែលអាចផ្តល់ឲ្យបាននោះ អាចឲ្យមេធាវីការពារក្តីកំណត់ថាតើខ្លួនត្រូវធ្វើសំណូមពរអ្វីទៀត និងអាចជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ថាតើសក្ខីកម្ម និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាសង្ខេបរបស់ នង សុផង់ មានទម្ងន់កម្រិតណា។ ដូចនេះ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដែលបានស្តាប់ចម្លើយ នង សុផង់ ឲ្យផ្តល់ភស្តុតាងក្នុងសវនាការជាសាធារណៈក្រោមសម្បថ។

**ខ. អង្គជំនុំជម្រះសាលាដំបូងមានអំណាចទទួលយកសំណើនេះ**

៨. វិធាន ៩៣(១) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស៊ើបអង្កេត នៅពេលខ្លួនយល់ឃើញថាចាំបាច់[27]។ វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវថា ច្បាប់ និងនីតិវិធីជាធរមាន "*ត្រូវតែ* បកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ ... ជនជាប់ចោទ ... និងដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"[28]។ ពិតណាស់ ក្រៅពីនេះ អង្គជំនុំជម្រះសាលាដំបូង *អាច* ហើយដូចមានបង្ហាញនៅខាងក្រោមទាក់ទងនឹងភារកិច្ចជាសារវន្តរបស់ខ្លួន *គួរតែ* ស្វែងរកការបញ្ជាក់ នៅពេលចាំបាច់ ដើម្បីរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី។ អង្គបុរេជំនុំជម្រះបានសម្រេចថា "ដំណាក់កាលជំនុំជម្រះគឺជាឱកាស និងជាជម្រើស បន្ថែមសម្រាប់

---

[26] *ដូចខាងលើ*។

[27] វិធាន ៩៣(១) នៃវិធានផ្ទៃក្នុង គឺជាការចែងឡើងវិញនៃមាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[28] មានបន្ថែមការបញ្ជាក់។

មេធាវីការពារក្តីជំទាស់តវ៉ាទៅនឹងភាពអាចជឿជាក់បាននៃភស្តុតាង[29] ដែលចំណុចនេះក៏ត្រូវបានឯកភាពដោយ ក.ស.ច.ស ដែរ[30]។

៩. ក.ស.ព ទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានអំណាច ដើម្បីបញ្ជាក់ឲ្យបានច្បាស់នូវបញ្ហានានាដែលទាក់ទងនឹងសុចរិតភាពនៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស ជាពិសេសបញ្ហាទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាសង្ខេប ដែលរៀបចំឡើងដោយអ្នកស៊ើបអង្កេត ក.ស.ច.ស។ អំណាចនេះត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងជំហរ ដែលបានអនុវត្តកន្លងមកក្នុងពេលមានតម្រូវការឲ្យមានការបញ្ជាក់ពីភាពមិនប្រក្រតី ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាសង្ខេបរបស់ ក.ស.ច.ស។ ជាឧទាហរណ៍ នៅពេលខ្លួនដឹងថា អ្នកស៊ើបអង្កេត ក.ស.ច.ស (អ្នកស៊ើបអង្កេតដដែល ដែលបានជួបសម្ភាសន៍ជាមួយនឹង នង សុផង់) បានធ្វើការស្តាប់ចម្លើយសាក្សី អឿន តាន ដែល មិនបានកត់ត្រា ឬថតយកសំឡេង ក.ស.ព បានស្នើដល់អង្គជំនុំជម្រះសាលាដំបូងឲ្យពិចារណា ដើម្បីស្វែងរកការបញ្ជាក់ពី ក.ស.ច.ស និងបានថ្លែងថា ការបញ្ជាក់ដូចនេះ “អាចជួយដល់ការស្វែងរកការពិត ពីព្រោះតែមានវិសាលភាពសង្ស័យនៅពេលនេះ ទាក់ទងនឹងអ្វីដែលបានកត់ត្រាចូលទៅក្នុងកំណត់ត្រា និងអ្វីៗដែលបានកើតឡើងក្នុងពេលស្តាប់ចម្លើយ”[31]។ សំណើនេះសូមស្នើសុំដំណោះស្រាយដូចគ្នា នឹងដំណោះស្រាយដែល ក.ស.ព បានស្នើឡើង សម្រាប់ការបញ្ជាក់បំភ្លឺបញ្ហានានាទាក់ទងនឹងកិច្ចសម្ភាសន៍ជាមួយនឹងសាក្សី អឿន តាន។

---

[29] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ និងសេចក្តីសន្និដ្ឋានបន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា សុំឲ្យស្តាប់ចម្លើយសាក្សីមួយចំនួន ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D375/1/8, កថាខណ្ឌ ៥៧ និងកំណត់ជើងទំព័រ ៩២។

[30] ដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើរបស់ នួន ជា សុំស្តាប់ចម្លើយសាក្សី ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០ ឯកសារ D375 កថាខណ្ឌ ៨។ សូមមើលផងដែរ ដីកាសម្រេចលើសំណើសុំធ្វើប្រតិចារឹក ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D194/2 កថាខណ្ឌ ៤ ដែល ក.ស.ច.ស បានបញ្ជាក់ពាក់ព័ន្ធនឹងសំណើសុំកិច្ចស៊ើបសួរដើម្បីបញ្ជាក់ពីភាពមិនស៊ើសង្វាក់គ្នានៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីពីរផ្សេងគ្នារបស់ ក.ស.ច.ស ដែលធ្វើឡើងដោយសាក្សីតែម្នាក់ ថា “សហចៅក្រមស៊ើបអង្កេតមានមធ្យោបាយនីតិវិធីជាច្រើនដើម្បីបំភ្លឺពីសក្ខីកម្មដែលមានលក្ខណៈផ្ទុយគ្នា ទៅតាមការផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមសំណើរបស់ភាគី ជាពិសេសខ្លួនមានលទ្ធភាពក្នុងការឲ្យមានការស្តាប់ចម្លើយសាជាថ្មី ឬរៀបចំឲ្យមានការតទល់គ្នា។ ភាពផ្ទុយគ្នានេះក៏អាចត្រូវបានបំភ្លឺផងដែរនៅដំណាក់កាលនៃសវនាការ” (មានបន្ថែមការបញ្ជាក់)។

[31] ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E1/87.1 ទំព័រ ៥៣។

## គ. អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចទទួលយកសំណើនេះ

១០. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានរៀបចំការស្តាប់ចម្លើយមួយជាមួយ នង សុផង់ ដែលមិនបានកត់ត្រា ឬថតយកសំឡេង តែបាននិយាយយោងតិចៗទៅដល់ការស្តាប់ចម្លើយបែបនេះនៅក្នុងការស្តាប់ចម្លើយ នង សុផង់ នាពេលបន្ទាប់មកទៀតដែលបានកត់ត្រា ឬថតយកសំឡេង (ពោលគឺដោយនិយាយថា "ដូចដែលលោកបាននិយាយប្រាប់ខ្ញុំកាលពីម្សិលមិញ")។ ចំណុចនេះលេចឡើងជាទម្លាប់អនុវត្តន៍របស់អ្នកស៊ើបអង្កេត ចាយ ច័ន្ទតារាវណ្ណ និង Thomas Keuhnel គឺថា ពួកគេបានជួបសាក្សី រៀបចំកិច្ចសម្ភាសន៍សួរ និងឆ្លើយដោយពុំបានកត់ត្រា ឬថតយកសំឡេង ហើយបន្ទាប់មកពួកគេរៀបចំកិច្ចសម្ភាសន៍លើប្រធានបទដដែលដូចកិច្ចសម្ភាសន៍ពីលើកមុន ទោះបីមិនប្រើសំណួរ និងចម្លើយដដែលក៏ដោយ[32]។ កិច្ចសម្ភាសន៍ដែលបានកត់ត្រា និងថតយកសំឡេងនេះនឹងក្លាយជាចម្លើយសាក្សីដែល "ត្រឹមត្រូវ និងសុក្រឹត្យ"[33] ដែលយកមកបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ដោយពុំបាននិយាយ ឬទទួលស្គាល់ថា មានការរៀបចំកិច្ចសម្ភាសន៍ជាមុន ដោយមិនបានកត់ត្រា ឬថតយកសំឡេងនោះទេ។ ការពិត មេធាវីការពារក្តីបានលាតត្រដាងនូវឧទាហរណ៍មួយទៀតដែលអ្នកស៊ើបអង្កេតពីររូបរបស់ ក.ស.ច.ស បានប្រើប្រាស់ទម្លាប់អនុវត្តន៍បែបនេះនៅពេលស្តាប់ចម្លើយសាក្សីដែលមានលេខសម្គាល់ TCW-695[34]។ យុទ្ធសាស្ត្រនៃការស៊ើបអង្កេតបែបនេះរំលោភដល់វិធាន ២៥ ដែលចែងថា "ការសួរយកចម្លើយអាចត្រូវធ្វើឡើងដោយមិនចាំបាច់មានការថតយកសំឡេង ឬ ថតយករូបភាព *នៅពេលដែលកាលៈទេសៈរារាំងចំពោះការថត*

---

[32] ស្រដៀងគ្នានេះដែរ អ្នកស៊ើបអង្កេតទាំងពីររូបនេះបានជួបជាមុន និងបានស្តាប់ចម្លើយ អឿន តាន ដោយពុំបានកត់ត្រាឬថតយកសំឡេងនៃការស្តាប់ចម្លើយនោះទេ ហើយបន្ទាប់មកក៏ត្រឡប់មកវិញ ដើម្បីកត់ត្រា និងថតយកសំឡេងនៃការស្តាប់ចម្លើយជាមួយគាត់។ *សូមមើល* សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតយកសំឡេង នានាទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨, ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E224។

[33] ប្រតិចារឹក, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារ E1/23.1, ទំព័រ ២១-២៣ (ភាសាអង់គ្លេស) នៅពេលលោកចៅក្រម Lavergne សួរសំណួរទៅសាក្សី ឡុង នរិន្ទ អំពីកំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីការស្តាប់ចម្លើយរបស់គាត់ ដែលគាត់បានចុះហត្ថលេខា និងផ្តិតមេដៃនោះ (ទំព័រ ២២-២៣) (ភាសាអង់គ្លេស) និងដែលលោកចៅក្រម Lavergne ចង់ឲ្យចាត់ទុកថាជាការឆ្លុះបញ្ចាំង "យ៉ាងត្រឹមត្រូវ និងសុក្រឹត្យ" ចំពោះចម្លើយរបស់គាត់ដែលបានផ្តល់ដល់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស (ទំព័រ ២៣) (ភាសាអង់គ្លេស)។

[34] *សូមមើល* ឯកសារ D232/8R, ពីថិរៈវេលា ៥:៥៥ ដល់ ៦:០៥។

*នេះ។ ក្នុងករណីនេះ មូលហេតុដែលមិនអាចធ្វើការថតបានក្នុងពេលសួរយកចម្លើយ ត្រូវចុះក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ...*"[35]។

១១. អង្គជំនុំជម្រះសាលាដំបូងត្រូវស្វែងរកការបញ្ជាក់ពី ក.ស.ច.ស ចំពោះកាលៈទេសៈនៅជុំវិញកិច្ចសម្ភាសន៍សួរ និងឆ្លើយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងត្រូវទទួលបានចម្លើយពីអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ពីមូលហេតុដែលពួកគេខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមវិធាន ២៥ ក្នុងការផ្តល់នូវមូលហេតុដែលពុំបានកត់ត្រា ឬថតយកសំឡេង។ ភាពជឿជាក់បាន និងទម្ងន់ជាភស្តុតាងដែលអាចផ្តល់ឲ្យចម្លើយរបស់ នង សុផង់ នោះអាច*ត្រឹមតែ*សម្រេចបាន*យ៉ាងមានប្រសិទ្ធភាព* ដោយការវិភាគទៅលើកាលៈទេសៈដែលគាត់ផ្តល់ចម្លើយនេះប៉ុណ្ណោះ ជាពិសេសនៅពេលដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បង្វែរទិសចេញពីទម្លាប់អនុវត្តន៍ដែលតម្រូវដោយវិធាន និងនៅពេលដែលការចងចាំរបស់ នង សុផង់ ក្នុងតុលាការត្រូវបាន "រម្លឹកសាជាថ្មី" ដោយនិយាយយោងដល់ចម្លើយទាំងនេះ[36]។ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង ចៅក្រមប្រធានលោក និល ណុន បានទទួលស្គាល់ថា ភាពមិនប្រក្រតីនៅក្នុងការរៀបចំការស្តាប់ចម្លើយរបស់ ក.ច.ស.ច ជា "បញ្ហាសំខាន់ មិនមែនជាបញ្ហាធម្មតា"[37]។ បញ្ហាដែលពាក់ព័ន្ធនឹងចម្លើយរបស់ នង សុផង់ ដែលមិនបានកត់ត្រា ឬថតយកសំឡេងក៏មិនខុសគ្នាដែរ។

១២. គួរកត់សម្គាល់ថា ក្នុងពេលសួរដេញដោល ការចងចាំរបស់ នង សុផង់ ត្រូវបាន "រម្លឹកសាជាថ្មី" ដោយចម្លើយរបស់គាត់ពីមុន។ ឧទាហរណ៍ តាមរយៈសំណួរ-ចម្លើយដែលដកស្រង់ចេញពីប្រតិចារឹកថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២ បង្ហាញថា ការប្រើចម្លើយរបស់គាត់ដើម្បីរម្លឹកសាជាថ្មីនូវការចងចាំរបស់ នង សុផង់ ដូចខាងក្រោម៖

---

[35] គូសបញ្ជាក់បន្ថែម។

[36] នៅពេលប្រធានចៅក្រមលោក និល ណុន សួរសំណួរ នង សុផង់ បានឆ្លើយថា គាត់បានពិនិត្យឡើងវិញលើចម្លើយរបស់គាត់ជាមួយ ក.ស.ច.ស រួចហើយ មុននឹងមកផ្តល់សក្ខីកម្មដើម្បីរម្លឹកឡើងវិញនូវការចងចាំរបស់គាត់។ ប្រតិចារឹក, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E1/117.1, ទំព័រ ៣៥ (ភាសាអង់គ្លេស)។

[37] ប្រតិចារឹក, ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E1/100.1, ទំព័រ ៨៦ (ភាសាអង់គ្លេស)។ ស្រដៀងគ្នានេះដែរ ប្រធានចៅក្រមលោក និល ណុន បានទទួលស្គាល់ថា កាលៈទេសៈនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយ ជា សាយ ក៏មានភាពពាក់ព័ន្ធដែរ ដោយសារចម្លើយទាំងនេះមានអានុភាពទៅលើភាពដែលអាចជឿជាក់បានរបស់សាក្សី។ *សូមមើល* សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២, ទំព័រ ៦៣-៦៤ (ភាសាអង់គ្លេស)។

[នួង សុផង់]៖ ឆ៖ ... ហើយបើសិនណាជាមានបញ្ហាអីសម្ងាត់ខ្លាំង ជួនកាលគេមិនបាច់ធ្វើតាមទូរលេខទេ ជួនកាលគេមកជួប សំណើសុំជួបគណៈមជ្ឈិមផ្ទាល់តែម្តង។

[Tarik Abdulhak]៖ ស៖ ដូច្នេះតាមរយៈចម្លើយរបស់លោកនេះ តើលោកដឹងថា តើអ្នកណាដែលចូលមកដោយផ្ទាល់តែម្តង ដើម្បីជួបជាមួយមជ្ឈិមនេះ? អ្នកណាជាអ្នកដែលមកដោយផ្ទាល់តែម្តងដើម្បីជួបជាមួយខាងគណៈមជ្ឈិមនោះ?

[នួង សុផង់]៖ ឆ៖ ខ្ញុំមិនដឹងកិច្ចការរាក់ជ្រៅអីប៉ុន្មានទេបាទ ពោះរឿងនេះវាជាលាក់ការ ជាការណ៍របស់មជ្ឈិម។ ដូច្នេះការងាររបស់ខ្ញុំគឺមានសិទ្ធិត្រឹមតែបកប្រែសារ និងបញ្ជូនសារតែប៉ុណ្ណោះ ឯរឿងកិច្ចការលាក់ -- រាក់ជ្រៅរបស់មជ្ឈិមយ៉ាងណាៗ អ្នកណាមានសិទ្ធិចូល អ្នកណាមានសិទ្ធិមិនត្រូវចូល ខ្ញុំមិនដឹងទេបាទ សូមអរគុណបាទ។

[Tarik Abdulhak]៖ ស៖ *ខ្ញុំចង់ឲ្យលោកពន្យល់បន្ថែមទៀតថា តើចម្លើយរបស់លោកនេះអាចធ្វើឲ្យលោកចងចាំឡើងវិញបានទេ។* ចូលទៅដល់ឯកសារ E3/64 ដដែល។ ERN ជាភាសាខ្មែរ 00328035, ERN ជាភាសាបារាំង 00411703, និង ERN ជាភាសាអង់គ្លេស 00334053។ ខ្ញុំសូមលើកឡើងដោយសង្ខេបទេ។ សំណួរថា “តើសារទូរលេខមកពីភូមិភាគណា ដែលលោកបកប្រែ?”

ឆ៖ “ខ្ញុំបកប្រែគ្រប់ភូមិភាគទាំងអស់។ ដូចជាខ្លឹមសារការលើកទំបន់ប្រឡាយ ស្នើសម្ភារៈនេះសម្ភារៈនោះ សមាសភាពផ្ទៃក្នុងដែលនៅក្នុង និងបាតុភាពអ្វីដែលកើតឡើងនៅមូលដ្ឋាន។ ចំណែកសារ៉ាយគឺការរាយការណ៍អំពីខ្មាំងឬជនក្បត់ គឺគណៈភូមិភាគមកជួបផ្ទាល់ជាមួយគណៈមជ្ឈិម”។

តើនេះគឺជាចម្លើយរបស់លោកដែលត្រឹមត្រូវ ដែលលោកឆ្លើយជូបសហចៅក្រមស៊ើបអង្កេតនោះ ឬក៏យ៉ាងណា ដែលលោកថា គឺគណៈភូមិភាគជាអ្នកមកជួបផ្ទាល់ជាមួយគណៈមជ្ឈិមនោះ?

[នួង សុផង់]៖ ឆ៖ បាទ ចម្លើយនេះគឺខ្ញុំអត់មានកែប្រែទេ ពីព្រោះថាភាគច្រើន

> កិច្ចការផ្ទៃក្នុងដែលធ្វើតាមរយៈសារទូរលេខមានតិចតួចណាស់ ដែលខ្ញុំស្ទើរតែមិនសូវដឹង។ តែភាគច្រើនគឺថា គេអាច បើមានផ្ទៃក្នុង គេមិន -- កន្លែងខ្លះក៏គាត់មិនអាចធ្វើតាមទូរលេខ ដើម្បីឲ្យបែកការខ្ចរខ្ចាយដែរ គឺគេអាចមកជួបផ្ទាល់ពិភាក្សាជាមួយគណៈមជ្ឈិមផ្ទាល់តែម្តងបាន[38]។

ប្រតិចារឹកនៃសវនាការនេះបង្ហាញថា មានប្រហែល ២៥ កន្លែង ដែល ក.ស.ព ឬ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអានផ្នែកខ្លះនៃចម្លើយរបស់ នង សុផង់ និងបានសួរឲ្យគាត់បញ្ជាក់ពីភាពសុក្រឹត្យនៃចម្លើយទាំងនោះ ឬ បានសុំឲ្យគាត់ផ្តល់ព័ត៌មានបន្ថែមទៀត[39]។

១៣. អង្គជំនុំជម្រះសាលាដំបូងគួរតែចាត់វិធានការសមហេតុផល និងចាំបាច់ទាំងអស់ ដើម្បីលាតត្រដាងពីភាពមិនប្រក្រតីនានារបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ជាពិសេសនៅពេលដែលភាពមិនប្រក្រតីទាំងនេះមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យបានខិតទៅជិតការពិតតាមតែអាចធ្វើបាន[40]។ អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿងអស់រយៈពេលពីរឆ្នាំមកហើយ ចាប់តាំងពីពេលចេញដីកាដំណោះស្រាយនៅខែ កញ្ញា ឆ្នាំ ២០១០[41]។ ដូចមេធាវីនៅ អ.វ.ត.ក ត្រូវបំពេញការងារប្រកបដោយការយកចិត្តទុកដាក់ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ក៏មានកាតព្វកិច្ចបំពេញការងារប្រកបដោយយកចិត្តទុកដាក់ដែរ។ មាត្រា ៥ នៃក្រមសីលធម៌ចៅក្រមនៅ អ.វ.ត.ក ចែងថា "ចៅក្រមត្រូវបំពេញតួនាទីរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ។ ... ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ"។ អនុលោម

---

[38] ប្រតិចារឹក, ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/120.1, ទំព័រ ១៦១៨ (គូសបញ្ជាក់បន្ថែម) (ភាសាអង់គ្លេស)។

[39] ប្រតិចារឹក, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E1/117.1, ទំព័រ ៣៥, ៦៥-៦៦, ៦៩, ៧៣ (ភាសាអង់គ្លេស); ប្រតិចារឹក, ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/120.1, ទំព័រ ១៣-១៤, ២២-២៣, ៣២, ៣៤-៣៥, ៤០, ៥៨-៦២, ៧៦, ៨៥-៨៧, ៩១-៩៣ (ភាសាអង់គ្លេស); ប្រតិចារឹក, ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/121.1, ទំព័រ ១៧-២០, ៣៤-៣៦, ៥១-៥៤, ៥៧-៥៩ (ភាសាអង់គ្លេស)។

[40] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៣១៨; វិធាន ៨៥(១)។ *សូមមើលផងដែរ* វិធាន ២១។

[41] វិធាន ៦៩(៣) ចែងថា៖ "ការដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ"។

តាមប្រព័ន្ធច្បាប់ស៊ីវិលដែលយកមកអនុវត្តនៅ អ.វ.ត.ក នេះ អង្គជំនុំជម្រះសាលាដំបូងគួរបានអាន និងវិភាគទៅលើសំណុំរឿងទាំងមូល មុនពេលសវនាការ ដើម្បីសម្រេចថាតើ សាក្សីរូបណាគួរនឹងកោះហៅមកផ្តល់សក្ខីកម្ម ហើយតើភស្តុតាងឯកសារណាមួយដែលនឹងត្រូវយកមកប្រើប្រាស់នៅពេលសវនាការ។ ដំណើរការពិនិត្យឡើងវិញនោះនឹងរួមទាំងការពិនិត្យឡើងវិញទៅលើខ្សែអាត់សំឡេងស្តាប់ចម្លើយសាក្សី និងប្រៀបធៀបខ្សែអាត់ទាំងនោះជាមួយនឹងសេចក្តីសង្ខេបដែល ក.ស.ច.ស បានរៀបចំ។

១៤. អាស្រ័យហេតុនេះ ប្រសិនបើភាពខុសគ្នារវាងការស្តាប់ចម្លើយដែលរៀបចំឡើងដោយ ក.ស.ច.ស ជាមួយ នួន ជា និងសាក្សីដទៃទៀត ជាមួយនឹងខ្សែអាត់ថតសំឡេង (ឬមិនបានថតយកសំឡេង) មានភាពធ្ងន់ធ្ងរពេកនោះ បន្ទាប់ពីបានពិនិត្យឡើងវិញទៅលើសំណុំរឿងទាំងមូលដូចដែលត្រូវបានតម្រូវឲ្យធ្វើ មុននឹងចាប់ផ្តើមបើកសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងប្រាកដជាបានកត់សម្គាល់ពីភាពខុសគ្នាទាំងនោះមិនខាន។ ដោយពិចារណាទៅដល់ភារកិច្ចរបស់ចៅក្រមនៅ អ.វ.ត.ក ក្នុងការរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនោះ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង (ដូចដែលកំពុងស្នើសុំនាពេលនេះ) គួរតែបានអនុវត្តនូវ*ភារកិច្ចពីធម្មជាតិ*របស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងភាពមិនប្រក្រតីនានា[42] ដោយមិនគិតដល់ផលវិបាកនានា ដូចជាការដែលបណ្តាលឲ្យ

[42] ក្រមសីលធម៌ចៅក្រមនៅ អ.វ.ត.ក, មាត្រា ៣(១) ចែងថា៖ "ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និងដោយសេចក្តីសុចរិតទៀងត្រង់តាមការិយាល័យរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ"; មាត្រា ៥៖ "១. ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន ដើម្បីបំពេញភារកិច្ចទាំងនោះ ... ៣. ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ"។ *សូមមើលផងដែរ* គោលការណ៍នៃក្រមសីលធម៌ចៅក្រមនៅ Bangalore (២០០២"), ក្បាលទី ៣, ការអនុវត្តន៍៖ "៣.១. ចៅក្រមត្រូវធានាថាការប្រព្រឹត្តរបស់ខ្លួនត្រូវនៅពីលើការរិះគន់នៃទស្សនៈរបស់អ្នកសង្កេតការណ៍ដែលសមហេតុផល។ ៣.២. ឥរិយាបថ និងការប្រព្រឹត្តរបស់ចៅក្រមត្រូវបញ្ជាក់ឡើងវិញនូវជំនឿទុកចិត្តរបស់ប្រជាជន ចំពោះសុចរិតភាពរបស់ស្ថាប័នតុលាការ។ *យុត្តិធម៌មិនត្រឹមតែធ្វើឲ្យបាននោះទេ តែក៏ត្រូវធ្វើឲ្យគេមើលឃើញថាបានធ្វើដែរ*"។ (គូសបញ្ជាក់បន្ថែម); ក្បាលទី ៦.២, ការអនុវត្តន៍៖ "ចៅក្រមត្រូវបូជាសកម្មភាពវិជ្ជាជីវៈជាចៅក្រមចំពោះភារកិច្ចផ្នែកយុត្តិធម៌ ដែលរួមទាំងមិនកំណត់ត្រឹមតែ ការបំពេញមុខងារ និងការទទួលខុសត្រូវផ្នែកយុត្តិធម៌នៅតុលាការ និងការចេញសេចក្តីសម្រេច តែក៏មានកាតព្វកិច្ចការងារដទៃទៀតដែរដែលពាក់ព័ន្ធនឹងមុខងារផ្នែកយុត្តិធម៌ ឬដំណើរការរបស់តុលាការ"; *ដូចខាងលើ,* ក្បាលទី ៦.៥, ការអនុវត្តន៍៖ "ចៅក្រមត្រូវបំពេញមុខងារទាំងអស់ផ្នែកយុត្តិធម៌ រួមទាំងការចេញសេចក្តីសម្រេចបម្រុងយ៉ាងមានប្រសិទ្ធភាព សមរម្យ និងត្រឹមត្រូវមានភាពសមហេតុសមផល"។ គោលការណ៍នៃក្រមសីលធម៌ចៅក្រមនៅ Bangalore ឆ្នាំ ២០០២ មានការសិក្សាមួយក្នុងចំណោមក្នុងសិក្សា

សហការី ឬបុគ្គលិករបស់ខ្លួននៅ ក.ស.ច.ស រងការអាម៉ាស់ ឬចាត់ទុកដំណើរការស៊ើបអង្កេតរបស់ពួកគេការធ្វើឲ្យមានអាប់ឱនជាដើម។ ការណ៍ដែលថា អង្គជំនុំជម្រះសាលាដំបូងមិនបានលើកឡើង*ដោយឯកឯង* (*sua sponte*) ពីភាពមិនប្រក្រតីនៅក្នុងការស្តាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយ នង សុផង់ និងសាក្សីដទៃទៀតនោះបង្ហាញថា អ្នកស៊ើបអង្កេតអាចលាក់បាំងភាពមិនប្រក្រតីទាំងនេះដោយអាចគេចផុតពីការចាប់អារម្មណ៍របស់អង្គជំនុំជម្រះសាលាដំបូងបាន។ ដោយសារអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស រៀបចំការស្តាប់ចម្លើយរបស់ខ្លួនរបៀបជាការក្លែងធ្វើពុត ដោយរៀបចំឲ្យមានការហាត់សមយ៉ាងសម្ងាត់ មុននឹងការស្តាប់ចម្លើយពិតប្រាកដមកដល់នោះ មេធាវីការពារក្តីពុំមានសមត្ថភាពខ្ពស់ជាងអង្គជំនុំជម្រះសាលាដំបូង ក្នុងការលាតត្រដាងនូវភាពខុសគ្នានោះទេ។

## ឃ. មេធាវីការពារក្តីមានសិទ្ធិបង្ហាញពីកំហុសឆ្គងក្នុងកិច្ចស៊ើបសួរ

១៥. មេធាវីការពារក្តីមិនបានរង់ចាំឲ្យកិច្ចស៊ើបសួររបស់ ក.ស.ច.ស បញ្ចប់ទៅដោយមិនបានធ្វើនោះទេ ហើយមិនបានបោះបង់ឱកាសក្នុងការជំទាស់ទៅនឹងកិច្ចស៊ើបសួរនេះក្នុងពេលសវនាការទេ ដូចដែលចៅក្រម Lavergne បាននិយាយបញ្ឆិតបញ្ឆៀងនៅពេលគាត់សួរថា៖ "*តើមេធាវីការពារក្តីធ្វើអ្វីខ្លះនៅក្នុងអំឡុងរយៈពេលប៉ុន្មានឆ្នាំនៃកិច្ចស៊ើបសួរនេះ? នេះជាសំណួររបស់ខ្ញុំ*"[43]។ ជាងបីឆ្នាំមុន មេធាវីការពារក្តីបានទទួលស្គាល់ថា ក.ស.ច.ស មិនបានរៀបចំកិច្ចស៊ើបសួររបៀបដែលមានការរៀបចំត្រឹមត្រូវ និងមានតម្លាភាពទេ។ ដោយពុំពេញចិត្តចំពោះការពុំមានតម្លាភាពដែលជ្រាបចូលក្នុងដំណើរការស៊ើបអង្កេតរបស់ ក.ស.ច.ស រួមទាំងទម្លាប់អនុវត្តន៍របស់ ក.ស.ច.ស ដែលដាក់តែ*អត្ថបទសង្ខេប*នៃការស្តាប់ចម្លើយសាក្សីទៅក្នុងសំណុំរឿង (ជាជាងដាក់ប្រតិចារឹកទាំងស្រុង) នោះ មេធាវីការពារក្តីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរមួយ ដោយកត់សម្គាល់*ក្នុង*

---

ដំបូងស្តីពីក្រមសីលធម៌របស់ចៅក្រម និងមានបំណងយកទៅអនុវត្តចំពោះចៅក្រមទូទាំងពិភពលោក។ គោលការណ៍ទាំងនេះត្រូវបានយកទៅពិនិត្យឡើងវិញ និងកែសម្រួលដោយអនុលោមទៅតាមបទអត្ថាធិប្បាយពីយុត្តាធិការផ្នែកច្បាប់ស៊ីវិល និងខំមិនឡូជាច្រើន។ សម្រាប់ការពិពណ៌នាពីដំណើរការនេះ *សូមមើល* ក្រុមសុចរិតភាពផ្នែកតុលាការ, បទអត្ថាធិប្បាយទៅលើ គោលការណ៍នៃក្រមសីលធម៌ចៅក្រមនៅ Bangalore, ខែ មីនា ឆ្នាំ ២០០៧, ទំព័រ ៩-១៨ (ភាសាអង់គ្លេស), អាចរកបាននៅលើគេហទំព័រ៖ http://www.coe.int/t/dghl/cooperation/ccje/textes/BangalorePrinciplesComment.PDF។

[43] ប្រតិចារឹក, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/123.1, ទំព័រ ៣៦ (ភាសាអង់គ្លេស) (គូសបញ្ជាក់បន្ថែម)។

*ចំណោមចំណុចផ្សេងទៀត*ថា "ការប្រមូលចងក្រងនូវការស្តាប់ចម្លើយរបស់សាក្សី ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដោយចិត្តឯងជាញឹកញាប់រាប់ខែ បន្ទាប់ពីការស្តាប់ចម្លើយនោះត្រូវបានធ្វើឡើង ជាមួយនឹងការពន្យល់បន្តិចបន្តួច ឬគ្មានតែម្តងថាតើ ការស្តាប់ចម្លើយនោះត្រូវបានធ្វើឡើងយ៉ាងដូចម្តេច ដើម្បីឱ្យសមស្របទៅនឹងកិច្ចស៊ើបសួរនោះ" និងថា "គ្មានអ្វីជាតឹកតាងបញ្ជាក់ថាភស្តុតាងដោះបន្ទុកនោះពិតជាត្រូវបានស្វែងរកដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មែននោះ។ ព័ត៌មានដែលបាត់បង់នេះមានឥទ្ធិពលដោយផ្ទាល់ទៅលើរបៀបវាយតម្លៃចំពោះសេចក្តីសន្និដ្ឋានលើអង្គហេតុដែលបានធ្វើដោយ ក.ស.ច.ស"[44]។

១៦. នៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរនេះ មេធាវីការពារក្តីបានស្នើសុំនូវព័ត៌មាននានាដូចខាងក្រោម៖

**ក.** ច្បាប់នីតិវិធីប្រើប្រាស់ដោយ ក.ស.ច.ស និងអ្នកស៊ើបអង្កេតរបស់ខ្លួន។

**ខ.** ផែនការ និងយុត្តិសាស្ត្រទាំងមូលនៃកិច្ចស៊ើបសួរ។

**គ.** គុណវុឌ្ឍិ និងបទពិសោធន៍របស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងនីតិវិធីប្រតិបត្តិការជាមូលដ្ឋានរបស់ពួកគេ។ និង

**ឃ.** ការប្រមូល និងការវិភាគលើភស្តុតាងដោះបន្ទុកដោយ ក.ស.ច.ស។ ចំណុចនេះក្រសោបបញ្ចូលទាំងព័ត៌មានទាក់ទងនឹងទ្រឹស្តីជម្រើស នៃអង្គហេតុផ្សេងពីអង្គហេតុរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវពិចារណាដោយ ក.ស.ច.ស និងព័ត៌មានស្តីពីថាតើ ទ្រឹស្តីជម្រើសទាំងនេះត្រូវបានគេប្រើប្រាស់យ៉ាងដូចម្តេចទៅក្នុងប្រព័ន្ធសម្រាប់កំណត់ ប្រមូល និងការវិភាគភស្តុតាងដោះបន្ទុក[45]។

១៧. មេធាវីការពារក្តីបានស្នើសុំជាពិសេសនូវព័ត៌មានដើម្បីបន្ថែមក្នុងសំណុំរឿង ដូចជា "សុវត្ថិភាពត្រូវបានដាក់ឱ្យអនុវត្តដើម្បីធានាថា ការស៊ើបសួរត្រូវបានធ្វើឡើងក្នុងរបៀបយ៉ាងដូច្នោះ អញ្ចឹងហើយវាមិនរំលោភបំពានសិទ្ធិរបស់ជនសង្ស័យ ... និងដើម្បីធានាឱ្យមានការការពារជាអតិបរមា និងការ

---

[44] សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីបី របស់លោក អៀង សារី, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩, ឯកសារ D171, កថាខណ្ឌ ៣ សេចក្តីផ្តើម។

[45] *ដូចខាងលើ,* កថាខណ្ឌ ៧។

ថែរក្សាភស្តុតាង" ដែលរួមទាំងការថែរក្សាខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយផងដែរ និង "ថាតើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានរក្សាទុកនូវបញ្ជីសំណួរដែលពួកគេបានសួរទៅបុគ្គលដែលពួកគេបានស្តាប់ចម្លើយឬទេ"[46]។ មេធាវីការពារក្តីបានកត់សម្គាល់ថា "សារៈសំខាន់របស់វិធីសាស្ត្រជាប្រព័ន្ធដើម្បីកំណត់ ប្រមូល និងវិភាគភស្តុតាងដោះបន្ទុកបែបនេះ មិនអាចមើលរំលងបានទេ [ពីព្រោះ] វាជាមូលដ្ឋានគ្រឹះសម្រាប់ការស៊ើបសួរដោយយុត្តិធម៌ អនាគតិ និងប្រកបដោយសមត្ថភាព"[47]។ សំណើជាក់លាក់នេះពាក់ព័ន្ធនឹងវិធីសាស្ត្រជាប្រព័ន្ធដើម្បីប្រមូលភស្តុតាងដោះបន្ទុកស្រដៀងនឹងតម្រូវការចាំបាច់ឲ្យមានវិធីសាស្ត្រ ដែលមានក្បួនខ្នាត និងជាប្រព័ន្ធដើម្បីប្រមូលភស្តុតាង*គ្រប់ប្រភេទ*។

១៨. ក.ស.ច.ស បានឆ្លើយតបវិញជាលិខិតដែលមានកម្រាស់ ១២ ទំព័រ ដោយនិយាយការពារខ្លួន ហើយខកខានមិនបានផ្តល់ព័ត៌មានជាក់ស្តែងដែលបានស្នើសុំនោះទេ។ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សីវិញ ក.ស.ច.ស បានអះអាង (ដែលពេលនេះមើលទៅដូចជាមិនបានសុក្រឹត្យ) ថា៖

> ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សីវិញ កំណត់ហេតុនៃការស្តាប់ចម្លើយសុទ្ធតែមានចុះនិទ្ទេសដែលបញ្ជាក់អំពីការគោរពតាមនីតិវិធីសំខាន់ៗទាំងអស់ ...។ ស្ទើរតែគ្រប់ករណីទាំងអស់ ការស្តាប់ចម្លើយត្រូវបានថតសំឡេង ...។ កំណត់ហេតុនៃការស្តាប់ចម្លើយមានបង្ហាញអំពីសំណួរដែលសួរ និងចម្លើយរួចហើយ។ ដូចដែលបានពន្យល់នៅខាងលើ ការស្តាប់ចម្លើយត្រូវបានថតជាសំឡេងជាលក្ខណៈស្វ័យប្រវត្តិ[48]។

ដូចដែលយើងដឹងនាពេលនេះគឺថា កិច្ចស៊ើបសួរ*មិន*គោរពតាមលក្ខខណ្ឌតម្រូវទាំងអស់ទេ។ អ្នកស៊ើបអង្កេតបានរំលោភវិធាន ២៥ ដោយខកខានមិនបានកត់ត្រា ឬថតយកសំឡេងនៃការស្តាប់ចម្លើយពីដំបូង ឬមិនបានពន្យល់ពីមូលហេតុដែលមិនបានកត់ត្រា ឬថតយកសំឡេង ឬថតវីដេអូ។

---

[46] *ដូចខាងលើ,* កថាខណ្ឌ២៨។

[47] *ដូចខាងលើ,* កថាខណ្ឌ៣៨ (គូសបញ្ជាក់បន្ថែម)។

[48] លិខិតពី ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តីដែលមានចំណងជើងថា ""សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ" ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត", ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D171/5, កថាខណ្ឌ ២៦, ៣៣ (ដើងទំព័រលប់ចោល)។

១៩. ប្រសិនបើ ក.ស.ច.ស ផ្តល់ព័ត៌មានដែលបានស្នើសុំមែននោះ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធីនោះ មេធាវីការពារក្តីស្ថិតក្នុងជំហរមួយដើម្បីបង្ហាញថា កិច្ចស៊ើបសួរត្រូវបានអនុវត្តប្រកបដោយគ្មានសណ្តាប់ធ្នាប់ និងទាបជាងបទដ្ឋានកំណត់។ ក.ស.ច.ស មានកាតព្វកិច្ចរៀបចំកិច្ចស៊ើបសួរដោយឥតលម្អៀង ក្នុងគោលបំណងដើម្បីស្វែងរកការពិត[49] ដោយមានគោលដៅចម្បងគឺចេញដីកាដំណោះស្រាយ ឬដីកាច្រានចោលការចោទប្រកាន់[50]។ បើតាមប្រព័ន្ធនីតិវិធីនៅ អ.វ.ត.ក មេធាវីការពារក្តី*គួរ*មានលទ្ធភាពពឹងផ្អែកលើកិច្ចស៊ើបសួរ*អញ្ញាក្រឹត្យ* របស់ ក.ស.ច.ស និងមិនគួរមានភារកិច្ចជាអ្នកពិនិត្យទៅលើថា តើ ក.ស.ច.ស បានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយសីលធម៌ និងយ៉ាងសុក្រឹត្យនោះទេ។ មេធាវីការពារក្តីមានសិទ្ធិទទួលបាន*ការពន្យល់ដោយមានសំអាងហេតុត្រឹមត្រូវ* ថា កិច្ចស៊ើបសួររបស់ ក.ស.ច.ស ត្រូវបានធ្វើឡើងតាមលក្ខណៈសមរម្យ និងជាប្រព័ន្ធ។ ការលាក់បាំងអ្វីៗចំពោះការស្តាប់ចម្លើយជាមុនដោយមិនបានកត់ត្រា ឬថតយកសំឡេង[51] និងបើតាមអ្នកបកប្រែភាសាដែលមានវត្តមានក្នុងពេលស្តាប់ចម្លើយរបស់ ភី ភួន ដែលបានលើកឡើងនៅក្នុងការស្តាប់ចម្លើយដែលមានកត់ត្រា និងថតយកសំឡេងមួយយ៉ាងតិចនោះ[52] អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានធ្វើឲ្យមេធាវីការពារក្តីមានទំនុកចិត្តទាល់តែសោះ។

២០. ទោះបីមេធាវីការពារក្តីមិនមានសិទ្ធិរៀបចំកិច្ចស៊ើបសួរដោយខ្លួនឯង និងការពិតត្រូវបានទទួលការព្រមានមិនឲ្យធ្វើបែបនេះទៀតផងនោះ[53] ក៏ដោយ ក៏មេធាវីការពារក្តីបានធ្វើការយ៉ាងយកចិត្តទុកដាក់ក្នុងនាមលោក អៀង សារី ជាមួយនឹងធនធានរបស់ខ្លួនដែលមានកម្រិត។ បន្ថែមទៅលើការ

---

[49] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ២៣ថ្មី; វិធាន ៥៥(១), (៥)។

[50] វិធាន ៦៧(១)។

[51] *សូមមើល* សំណើរបស់ អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកជាការលេងផ្តិតផ្អែក, ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E221។

[52] *ដូចខាងលើ*។

[53] *សូមមើល* លិខិតពី ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី នួន ជា ដែលមានចំណងជើងថា៖ ការឆ្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការស៊ើបអង្កេត, ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨, ឯកសារ A110/I, ទំព័រ ២ (ភាសាអង់គ្លេស)។

ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួន ១២ ក្នុងអំឡុងពេលកិច្ចស៊ើបអង្កេតនោះ មេធាវីការពារក្តីបានពិនិត្យឡើងវិញទៅលើសម្ភារៈឯកសារដែលបានដាក់ក្នុងសំណុំរឿង។ ទោះជាយ៉ាងណាក្តី ដោយសារចំនួនដ៏ច្រើននៃឯកសារដែលបានដាក់/កប់ក្នុងសំណុំរឿង និងដោយសារធនធានដ៏តិចតួចស្តួចស្តើងរបស់មេធាវីការពារក្តីនោះ[54] យើងខ្ញុំពុំអាចពិនិត្យឡើងវិញឲ្យបានពេញលេញទៅលើភស្តុតាង*ទាំងអស់*បានទេ។ គិតមកដល់ពេលចេញដីកាដំណោះស្រាយនៅ ខែ កញ្ញា ឆ្នាំ ២០១០ មានឯកសារជាភាសាអង់គ្លេសចំនួន **៣១.៦២៧** នៅក្នុងសំណុំរឿង (រួមទាំងសារណាដែលភាគីបានដាក់ និងសម្ភារៈគាំទ្រផ្សេងទៀត ដោយមិនរាប់បញ្ចូលឯកសារជាភាសាខ្មែរ និងបារាំងទេ) ដែលរួមមានប្រហែល **១៥០.៩៣៩** ទំព័រ។ ប្រសិនបើមេធាវីការពារក្តីត្រូវពិនិត្យឡើងវិញតែចំពោះឯកសារជាភាសាអង់គ្លេស*ប៉ុណ្ណោះ* ក៏ត្រូវចំណាយពេលដល់ទៅ **៧៥៥** ថ្ងៃដែរ ដោយអាន **២០០** ទំព័រក្នុងមួយថ្ងៃ ដើម្បីពិនិត្យឡើងវិញទៅលើសម្ភារៈឯកសារនេះ។ បន្ថែមទៅលើភស្តុតាងជាឯកសារ មានខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សីចំនួន **៨៤៦** ដែល ក.ស.ច.ស បានរៀបចំបញ្ចូលក្នុងសំណុំរឿង (មិនរាប់បញ្ចូលខ្សែអាត់សំឡេង និងរូបភាពដែលរៀបចំដោយអ្នកសិក្សាស្រាវជ្រាវពីខាងក្រៅដែល ក.ស.ច.ស បានដាក់ក្នុងសំណុំរឿងផងទេ) ដោយរួមមានខ្សែអាត់ដែលមានរយៈពេល **១.៧៦៧** ម៉ោង។ ប្រសិនបើមេធាវីការពារក្តីមានពេលទំនេរ *មិនធ្វើអ្វីសោះ* ក្រៅតែពីការស្តាប់ខ្សែអាត់សំឡេងទាំងនេះរយៈពេល ៨ ម៉ោងក្នុងមួយថ្ងៃនោះ ក៏មេធាវីការពារក្តីត្រូវចំណាយពេលដល់ទៅ **២២១** ថ្ងៃដែរ ទើបអាចពិនិត្យឡើងវិញទៅលើខ្សែអាត់សំឡេងទាំងអស់នេះបាន។

---

[54] ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញាលោក Tarik Abdulhak បានអះអាងដោយមិនត្រឹមត្រូវថា ធនធានរបស់ ក.ស.ព មានប្រហាក់ប្រហែលនឹងមេធាវីការពារក្តីដែរ។ ប្រតិចារឹក, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/123.1, ទំព័រ ៤០ (ភាសាអង់គ្លេស)។ ក.ស.ព ចាប់ផ្តើមស៊ើបអង្កេតលោក អៀង សារី នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៦។ *សូមមើល* ដីកាដំណោះស្រាយ, ឯកសារលេខ D427, កថាខណ្ឌ ៣។ មេធាវីការពារក្តីត្រូវបានហាមឃាត់មិនឲ្យបើកកិច្ចស៊ើបសួរដោយខ្លួនឯង។ *សូមមើល* លិខិតពី ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី នួន ជា ដែលមានចំណងជើងថា៖ ការឆ្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការស៊ើបអង្កេត, ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨, ឯកសារ A110/I, ទំព័រ ២ (ភាសាអង់គ្លេស)។ ក្រុមមេធាវីការពារក្តីមិនទាន់ទាំងបានបង្កើតឡើងផងរហូតទាល់តែជិតមួយឆ្នាំកន្លះក្រោយ។ ជាងនេះទៀត ក្នុងអំឡុងពេលកិច្ចសង្កេត ក.ស.ព មានជំនួយពីមន្ត្រីវិភាគដែលបម្រើការងារពេញម៉ោងជាច្រើននាក់ បន្ថែមទៅលើមន្ត្រីច្បាប់របស់ខ្លួន ចំណែកឯមេធាវីការពារក្តីមានតែមន្ត្រីវិភាគដែលបម្រើការងារក្រៅម៉ោងតែប៉ុណ្ណោះ។

២១. មេធាវីការពារក្តីពុំមានពេលទំនេរ ដើម្បីចំណាយទៅការពិនិត្យលើទម្លាប់នៃការស៊ើបអង្កេតរបស់ ក.ស.ច.ស ទេ ដោយសារមានបញ្ហាផ្នែកច្បាប់បន្ទាន់ និងសំខាន់ជាច្រើនដែលមេធាវីការពារក្តីត្រូវដោះស្រាយក្នុងពេលបើកកិច្ចស៊ើបសួរ។ ការខកខានមិនបានធ្វើបែបនេះនឹងមានន័យថា ជាការបោះបង់បញ្ហាទាំងនេះចោល មិនបំពេញការងារប្រកបដោយការយកចិត្តទុកដាក់ និងពុំមានផ្តល់ការតំណាងផ្លូវច្បាប់ពេញលេញដល់លោក អៀង សារី បាន។ គេគួររម្លឹកឡើងវិញថា អ.វ.ត.ក ជាស្ថាប័ន*មួយដោយឡែក (sui generis)* ហេតុនេះហើយ ច្បាប់សារជាតិ និងច្បាប់នីតិវិធីទាំងអស់ត្រូវតែយកមកពិនិត្យពិច័យ។ ជាក់ស្តែង បញ្ហានីមួយៗគឺជាបញ្ហាចំណាប់អារម្មណ៍ដំបូង[55]។

---

[55] មេធាវីការពារក្តីត្រូវតែលើកឡើងនូវបញ្ហាជាច្រើនដែលតម្រូវឱ្យមានដំណោះស្រាយ ដែលខ្លួនបានស្នើឡើងក្នុងចំណោមនោះរួមមានសារណានានាដូចជា៖ សារណារបស់លោក អៀង សារី អនុលោមតាម *សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី សុំការពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ,* ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២00៨, ឯកសារ C22/I/26; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D390/1/2/1.3; សំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក, ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារ D345/2; សំណើសុំជាជម្រើសរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក, ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារ D345/3; បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០, ឯកសារ D345/5/1; សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក, ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩, ឯកសារ D240; សំណើសុំរបស់ អៀង សារី ជំទាស់ទៅនឹងការអនុវត្តន៍អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនៅ អ.វ.ត.ក, ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារ D379; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនមនុស្សដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់, ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៩, ឯកសារ D180/4; សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានកិច្ចស៊ើបសួរស្តីអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ, ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩, ឯកសារ D188/3; ពាក្យសុំរបស់លោក អៀង សារី ប្រឆាំងទៅនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក, ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០, ឯកសារ D378; ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក, ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ D378/2; ញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែលមានចែងក្នុងមាត្រា ៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (បទល្មើសនៅក្នុងច្បាប់ជាតិ) នៅ អ.វ.ត.ក, ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ D382; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D390/1/2/1.3។

២២. សរុបមក ក្នុងពេលបើកកិច្ចស៊ើបសួរ មេធាវីការពារក្តីបានដាក់សារណាយ៉ាងហោចណាស់ចំនួន ២១៣ ដោយមិនរាប់បញ្ចូលលិខិតប្រាស្រ័យទាក់ទងចាំបាច់ និងមានសំអាងហេតុដទៃទៀត និងអនុស្សរណៈនានា[56]។ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley បានពន្យល់នៅក្នុងព្រឹត្តិប័ត្រព័ត៌មាន ខឺ ខេមបូឌា ដេលី បន្ទាប់ពីសវនាការបឋម (ក្នុងពេលដែលមានការពិភាក្សាទៅលើឧបសគ្គនៃយុត្តាធិការរបស់តុលាការ) គឺថា៖ "តុលាការនេះត្រូវបានបង្កើតឡើងមានលក្ខណៈពិសេស និងមានទំនាក់ទំនងទៅនឹងបញ្ហាបច្ចេកទេសច្បាប់កម្រិតខ្ពស់ដែលភាគីនានាត្រូវលើកឡើង ហើយចៅក្រមជាអ្នកសម្រេច។ លោក អាង ឧត្តម និង លោក Michael Karnavas គ្រាន់តែបំពេញការងាររបស់ខ្លួនប៉ុណ្ណោះ -- នោះជាអ្វីដែលយើងអាចរំពឹងបានពីពួកគេ"[57]។

២៣. វាជាការគ្រប់គ្រាន់ដែលនិយាយថា ថ្វីត្បិតតែមេធាវីការពារក្តីបំពេញការងារប្រកបដោយការយកចិត្តទុកដាក់ក៏ដោយ ក៏ចំណុចសំខាន់នៃបញ្ហានាពេលនេះគឺថា ក្នុងដំណាក់កាលនេះ តើអង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យមើលទៅលើភាពមិនប្រក្រតីទាំងនេះបានឬទេ ជាបញ្ហាមួយដែលមិនអាចជៀសវាងបាន និងហួសពីការស្តីបន្ទោសទៅទៀត។ កាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងដំណាក់កាលនេះគឺ រៀបចំកិច្ចស៊ើបសួរដែលបានស្នើសុំ ពីលក្ខណៈនៃការរៀបចំការស្តាប់ចម្លើយរបស់ នង សុផង់ រួមទាំងការពិនិត្យទៅលើភាពមិនប្រក្រតីដទៃទៀត ដែលអង្គបុរេជំនុំជម្រះបានពន្យល់យ៉ាងដូច្នេះថា៖

> [ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតមានន័យថា] ប្រសិនបើសហចៅក្រមស៊ើបអង្កេតអនុវត្តឆន្ទានុសិទ្ធិឲ្យបានត្រឹមត្រូវ ក្នុងការបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរណាមួយ ដូចជា សុំឲ្យស្តាប់ចម្លើយ ឬសាក្សីចម្លើយសាក្សីឡើងវិញនោះ ដំណាក់កាលជំនុំជម្រះបង្កលក្ខណៈឲ្យមេធាវីការពារក្តីមាន "ឱកាសទាំងអស់ដើម្បីជំទាស់តវ៉ាទៅលើភស្តុតាង" រួមទាំងលទ្ធភាព "ស្នើសុំឲ្យ

---

[56] ប្រសិនបើមានសំណើសុំ យើងខ្ញុំនឹងរៀបចំបញ្ជីនៃសារណាទាំងនេះដាក់ជូន។

[57] លោក Andrew Cayley, *ក្រុមមេធាវីការពារក្តី អៀង សារី ពុំចាំបាច់សូមអភ័យទោសចំពោះការបំពេញការងាររបស់ខ្លួនទេ (IENG Sary Defence Team Need Not Apologise for Doing Its Job)*, ព្រឹត្តិប័ត្រព័ត៌មាន ខឺ ខេបូឌា ដេលី ចេញផ្សាយថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១១។

អង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីណាម្នាក់ ដែលសហចៅក្រមស៊ើបអង្កេតបានសម្រេចមិនស្ដាប់ចម្លើយ (មិនស្ដាប់ចម្លើយឡើងវិញ)។ ចំណុចដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលអង្គជំនុំជម្រះសាលាដំបូងយល់ស្របនោះគឺថា ដំណាក់កាលជំនុំជម្រះគឺជាឱកាស និងជាជម្រើសបន្ថែមសម្រាប់មេធាវីការពារក្ដីជំទាស់តវ៉ាទៅនឹងភាពអាចឲ្យជឿជាក់បាននៃភស្តុតាង[58]។

## III. សេចក្ដីសន្និដ្ឋាន និងសំណូមពរ

២៤. អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចវិជ្ជាជីវៈតុលាការដើម្បីធានាថា ការជំនុំជម្រះត្រូវរៀបចំឲ្យបានត្រឹមត្រូវ ដោយ "មានការគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ" និងថា យុត្តាធិការរបស់ខ្លួនត្រូវបានអនុវត្តទៅតាមកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[59]។ អនុលោមតាមភារកិច្ចនេះ និងដូចដែលអនុញ្ញាតដោយវិធាន ៩៣ ផងដែរនោះ អង្គជំនុំជម្រះសាលាដំបូង*ត្រូវ*ស្វែងរកការបញ្ជាក់ពាក់ព័ន្ធនឹងកាលៈទេសៈនៃការស្ដាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយ នង សុផង់ ក៏បាន ឬទុកជាមោឃៈនូវចម្លើយនានា និងសក្ខីកម្មរបស់គាត់ជាមួយគ្នាតែម្ដងក៏បាន។ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលស្គាល់ថា ភារកិច្ចរបស់ខ្លួនក្នុងការស្វែងរកការពិតតម្រូវឲ្យខ្លួនត្រូវពិនិត្យពិច័យឲ្យបានហ្មត់ចត់ទៅលើភស្តុតាងនានា ដែលបានប្រមូលក្នុងពេលបើកកិច្ចស៊ើបសួរ និងពីលក្ខណៈនៃការប្រមូលភស្តុតាងទាំងនោះ។ ក្នុងការធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូងនឹងការពារ និងធានាថា សិទ្ធិជាសារវន្តរបស់លោក អៀង សារី ក្នុងការទទួលការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ដើម្បីពិនិត្យទៅលើភស្តុតាងដាក់បន្ទុក និងសិទ្ធិក្នុងការការពារខ្លួនផង ដែលនឹងរក្សានូវកេរដំណែលរបស់ អ.វ.ត.ក ជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជា។

---

[58] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ និងសេចក្ដីសន្និដ្ឋានបន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា សុំឲ្យស្ដាប់ចម្លើយសាក្សីមួយចំនួន, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D375/1/8, កថាខណ្ឌ ៥៧ (គូសបញ្ជាក់បន្ថែម)។

[59] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី។ *សូមមើលផងដែរ* ក្រមសីលធម៌ចៅក្រមនៅ អ.វ.ត.ក, មាត្រា ៥(១)៖ "ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្ដីសង្វាតព្យាយាម ..."។

**ហេតុដូច្នេះ** អាស្រ័យលើមូលហេតុដូចបានពោលខាងលើ មេធាវីការពារក្តីសូមស្នើដល់អង្គបុរេជំនុំជម្រះមេត្តា៖

ក. ស្វែងរកការបញ្ជាក់ពី ក.ស.ច.ស ថា៖

i. ថាតើ មានការកត់ត្រា ឬថតសំឡេងរបស់ នង សុផង់ ក្នុងពេលស្តាប់ចម្លើយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២00៩ ឬទេ។

ii. រយៈពេលនៃការស្តាប់ចម្លើយនោះ។

iii. បុគ្គលដែលមានវត្តមានក្នុងពេលស្តាប់ចម្លើយ។

iv. ឯកសារ និងសម្ភារៈនានាដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានបង្ហាញដល់ នង សុផង់ បើមាន។

v. ប្រសិនបើពុំមានការកត់ត្រា ឬថតសំឡេងទេ សូមបង្ហាញពីសំអាងហេតុដែលមិនបានកត់ត្រា ឬថតសំឡេង និងពីការសួរសំណួរដល់ នង សុផង់ ដោយមិនបានកត់ត្រា ឬថតសំឡេងនៃការស្តាប់ចម្លើយនោះ។ និង

ខ. ប្រសិនបើពិតជាមានកំណត់ត្រា ឬខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២00៩ មែននោះ សូមបញ្ចូលទៅក្នុងសំណុំរឿងសម្រាប់យកមកពិនិត្យឡើងវិញ និងការប្រើប្រាស់ដោយភាគីនានា។ និង

គ. កោះហៅអ្នកស៊ើបអង្កេតឲ្យមកផ្តល់ភស្តុតាងពាក់ព័ន្ធនឹងកាលៈទេសៈនៃការស្តាប់ចម្លើយរបស់ខ្លួនជាមួយ នង សុផង់ នៅថ្ងៃទី ១៧ និង ១៨ ខែ កុម្ភៈ ឆ្នាំ ២00៩។

សូមលោក លោកស្រីចៅក្រមអង្គបុរេជំនុំជម្រះមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៧** ខែ **កញ្ញា** ឆ្នាំ **២0១២**